# សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលៈ

## ទស្សនៈមួយចំនួនលើសេចក្តីព្រាងច្បាប់ទី៤

---

របាយការណ៍សង្ខេប

ខែធ្នូ ឆ្នាំ២០១១

បណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា
(CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)

## កាលប្រវត្តនៃអង្គការសង្គមស៊ីវិល

បណ្ដាញកសិករ និងធម្មជាតិ (FNN) គឺជាបណ្ដាញកសិករដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយលើកកម្ពស់ផលិតផលកសិកម្ម និងការពារផលប្រយោជន៍ជូនកសិករខ្មែរ។ FNN ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ដោយកសិករមួយក្រុម និងបានចាប់ដំណើរការមក ដោយបានទទួលការជួយជ្រោមជ្រែងពីមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)។ បច្ចុប្បន្ននេះ FNN កំពុងប្រតិបត្តិការនៅក្នុងខេត្តចំនួន ១៤ ទូទាំងប្រទេស ដែលមានសមាជិកជាសមាគមចំនួន ១,១០៧ សមាគម និងសមាជិកជាបុគ្គលសរុបជាង ៥០,០០០នាក់។

លោក ប៉ាន សុភាព នាយកប្រតិបត្តិបណ្ដាញកសិករ និងធម្មជាតិ (FNN)
អ៊ីម៉ែល: pansopheap@gmail.com
វែបសាយ: www.fnn.org.kh

សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) ត្រូវបានបង្កើតឡើងនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ តាមរយៈសហគមចំនួន ១២ ដែលធ្វើការរួមគ្នា ដើម្បីចង្អុលបង្ហាញពីសិទ្ធិដីធ្លី ធនធានធម្មជាតិ និងការបណ្ដេញចេញដោយបង្ខំ ដែលកើតចេញមកពីគម្រោងអភិវឌ្ឍនានាដែល ប៉ះពាល់ដល់ការរស់នៅរបស់កសិករ។ បច្ចុប្បន្ននេះ CCFC កំពុងធ្វើការងារជាមួយនឹងសហគមន៍ចំនួន ៧៤ ដែលជាតំបន់មានការប៉ះពាល់ដែលមាន ១០ ខេត្ត ជាតំបន់គោលដៅ។

លោក ថេង សាវឿន អ្នកសម្របសម្រួលសម្ព័ន្ធសហគមន៍កសិករកម្ពុជា
អ៊ីម៉ែល: ccfc.cambodia@gmail.com

សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៥ ដោយក្រុមកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាក្រុមអ្នករត់ម៉ូតូ អ្នកបើកបររថយន្តឈ្នួល អ្នកបើកបរម៉ូតូកង់បី អាជីវករ អ្នកបម្រើការងារក្នុងភោជនីយដ្ឋាន និងអ្នកផ្សព្វផ្សាយស្រាបៀរ ក្នុងគោលបំណងលើកកម្ពស់សិទ្ធិសេរីភាពរបស់កម្មករ។ សមាគម ក៏បានកសាងសមត្ថភាពតាមរយៈការផ្ដល់ការអប់រំដល់សមាជិករបស់ខ្លួនស្ដីពីច្បាប់ការងារទាក់ទងនឹងវិស័យទាំងនេះ បូករួមទាំងសុខភាព និងសុវត្ថិភាព។ សមាគម ក៏សកម្មក្នុងការធ្វើការតស៊ូមតិដោយសន្តិវិធីលើកកម្ពស់ការគោរព និងការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ IDEA មានសមាជិកជាបុគ្គលចំនួនជាង ៣,៥០០ នាក់ ក្នុងខេត្តចំនួន៥។

លោក ហេង សំអិន , អគ្គលេខាធិការ IDEA
អ៊ីម៉ែល: ideacambodia@gmail.com
វែបសាយ: www.ideacambodia.org

បណ្តាញយុវជនកម្ពុជា (CYN) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ ដោយក្រុមនិស្សិត និងយុវជនដើម្បីផ្តួចផ្តើមគំនិតជួយពង្រឹងអំណាចយុវជន និងលើកទឹកចិត្តឲ្យមានការចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ បណ្តាញធ្វើការជាមួយនឹងក្រុមយុវជននៅតាមវិទ្យាល័យ និងសកលវិទ្យាល័យនានា ក្នុងគោលបំណងលើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មក្នុងការការពារសិទ្ធិមនុស្ស ការពារសង្គម និងអភិរក្សវប្បធម៌។ បច្ចុប្បន្ននេះ CYN សមាជិកជានិស្សិតជាង ២០០ នាក់។

លោក ទឹម ម៉ាឡៃ ប្រធានបណ្តាញយុវជនកម្ពុជា
អ៊ីម៉ែល: contact.cyncambodia@gmail.com
វែបសាយ: http://cyn-cambodia.blogspot.com

អង្គការលីកាដូ (LICADHO) គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល លីកាដូ បានបន្តដើរតួជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាល តាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-ក្រុងផ្សេងទៀត។

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ
អ៊ីម៉ែល: contact@licadho-cambodia.org
វែបសាយ: www.licadho-cambodia.org

# ១. ទិដ្ឋភាពទូទៅ

កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ រដ្ឋាភិបាលកម្ពុជាបានចេញផ្សាយសេចក្តីព្រាងច្បាប់លើកទី៤ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ការចេញផ្សាយនេះ គឺមានរយៈពេលមួយឆ្នាំ បន្ទាប់ពីការចេញផ្សាយសេចក្តីព្រាងច្បាប់លើកទី១ ក្នុងពាក់កណ្តាលខែធ្នូ ឆ្នាំ២០១០។[១]

អត្ថបទនៃសេចក្តីព្រាងច្បាប់ទាំងបីលើកមុនៗ ទទួលនូវការរិះគន់ពីបណ្តាអង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិ រដ្ឋាភិបាលប្រទេសផ្តល់ជំនួយ និងក្រុមអ្នកវិភាគច្បាប់មួយចំនួន។ រដ្ឋាភិបាលបានទទួលស្គាល់នូវការរិះគន់ទាំងអស់នេះចំនួនពីរលើកមកហើយ ហើយបានសន្យានឹងផ្តល់នូវសេចក្តីព្រាងច្បាប់ថ្មី ដែលល្អប្រសើរជាងមុន។ តែផ្ទុយទៅវិញ រដ្ឋាភិបាលនៅតែមិនទាន់បានអនុវត្តនូវអ្វីៗដែលលោកបានសន្យាទាំងពីរលើកនេះទេ។

ជាមួយនឹងសេចក្តីព្រាងច្បាប់លើកទី៤ នេះ រដ្ឋាភិបាលនៅតែខកខានមិនទាន់បានធ្វើអ្វីៗដែលលោកបានសន្យាដដែល។

ទោះបីជាសេចក្តីព្រាងច្បាប់នេះ បានកាត់ចោលជាង ២០មាត្រា និងមាននូវចំណុចវិជ្ជមានគួរឲ្យកត់សំគាល់មួយចំនួនក៏ដោយ ក៏ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ នៅតែបន្សល់នូវភាពមិនច្បាស់លាស់កាន់តែច្រើនជាងសេចក្តីព្រាងច្បាប់លើកមុនទៅទៀត។ នៅក្នុងមាត្រាសំខាន់ៗមួយចំនួនធ្វើអោយមានចម្ងល់ជាច្រើន ទាំងក្នុងន័យការអនុវត្តន៍ច្បាប់ និងចេតនារបស់រដ្ឋាភិបាល។

ជាឧទាហរណ៍ នៅក្នុងសេចក្តីព្រាងច្បាប់បានបញ្ជាក់ថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក "អាចបង្កើតឡើងដោយសេរី" ដោយមិនចាំបាច់មានការអនុញ្ញាតពីរដ្ឋាភិបាលឡើយ ក៏ប៉ុន្តែបែរជាបដិសេធមិនទទួលស្គាល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលមិនបានចុះបញ្ជី នូវសមត្ថភាពតាមផ្លូវច្បាប់ក្នុងការអនុវត្តសកម្មភាពរបស់អង្គការទាំងនោះឡើយ។ តើការចុះបញ្ជីពិតជាត្រូវ បានលើកលែង ឬយ៉ាងណា?

អង្គការសហគមន៍មូលដ្ឋានមិនតម្រូវឲ្យចុះបញ្ជីតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប៉ុន្តែក្រុមអង្គការសហគមន៍មូលដ្ឋានទាំងនេះត្រូវបានកំណត់និយមន័យយ៉ាងរឹតត្បិត ដែលតាមការអនុវត្តជាក់ស្តែង ក្រុមអង្គការសហគមន៍មូលដ្ឋានស្ទើរតែមិនអាចអនុវត្តសកម្មភាព

---

[១] សេចក្តីព្រាងច្បាប់ទីមួយ បានចេញផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ ចំណែកឯសេចក្តីព្រាងច្បាប់ទីពីរបានចេញផ្សាយនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ និងសេចក្តីព្រាងច្បាប់ទីបីបានចេញផ្សាយនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១។

របស់អង្គការទាំងនោះឡើយ។ ត្រង់ចំនុចនេះ ធ្វើអោយមានចម្ងល់ថា តើបណ្តាញសកម្មជនព្រៃឈើមួយចំនួននៅតែជា "អង្គការសហគមន៍មូលដ្ឋាន" ឬយ៉ាងណា? ប្រសិនបើអ្នកទាំងនោះធ្វើសកម្មភាពខាងក្រៅឃុំ ឬសង្កាត់របស់ខ្លួន។

លើសពីនេះទៅទៀត អង្គការសហគមន៍មូលដ្ឋាន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ ឬសង្កាត់អំពីសកម្មភាពរបស់អ្នកទាំងនោះ និងមេដឹកនាំផងដែរ។ មាត្រានេះមិនអនុវត្តចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឡើយ។ តើដំណើរការនេះនឹងវិវឌ្ឍន៍ទៅរកការទាមទារនៃការ ចុះបញ្ជីដែរឬទេ?

សេចក្តីព្រាងច្បាប់នេះ មានផ្នែកសំខាន់ៗបីដែលទំនងកំណត់ឡើងដើម្បីនីតិបុគ្គលមិនយកចំណេញនៅក្នុងស្រុកទាំងអស់ ដែលមានបំណងបង្កើតនៅក្នុងប្រទេសកម្ពុជា។ ហេតុអ្វីចាំបាច់បង្កើតរបបនៃការចុះបញ្ជីថ្មីមួយទៀត (អនុវត្តចំពោះអង្គភាពជាច្រើនចាប់ពីសភាពាណិជ្ជកម្ម អង្គការមិនមែនរដ្ឋាភិបាលធំៗ រហូតដល់បណ្តាញសកម្មជនបរិស្ថាន) នៅខណៈពេលដែលរបៀបនៃការចុះបញ្ជី និងការបង្កើតនីតិបុគ្គលមិនយកចំណេញមានរួចទៅហើយនៅក្នុងក្រមរដ្ឋប្បវេណីនោះ?

នៅក្នុងមាត្រា ដែលពិបាកយល់មួយគឺថា "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃ" នឹងត្រូវបានក្រសួងមហាផ្ទៃចាត់ទុកថា "បានបោះបង់សកម្មភាពរបស់ខ្លួនហើយ" ប្រសិនបើ អង្គការទាំងនោះ មិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់រដ្ឋាភិបាលស្តីពីការបន្តសកម្មភាពរបស់ខ្លួន។ តើនេះស្របទៅនឹងសេចក្តីព្រាងច្បាប់ដែលបានអះអាងនៅចំណុចផ្សេងទេ? ដែលថា អង្គការមិនមែនរដ្ឋាភិបាលអាចបង្កើតឡើងដោយមិនចាំបាច់ចុះបញ្ជីនោះ។

ជាមួយគ្នានេះផងដែរ បញ្ហាជាក់លាក់មួយចំនួននៅតែមានបន្សល់ពីសេចក្តីព្រាងច្បាប់មុនៗ។ ដូចជា ពុំមាននីតិវិធីផ្នែករដ្ឋបាលសម្រាប់ករណី ដែលក្រសួងបដិសេធក្នុងការចុះបញ្ជី។ បណ្តឹងតវ៉ា គឺមានតែមួយគត់ គឺត្រូវប្តឹងដោយផ្ទាល់ទៅតុលាការតែប៉ុណ្ណោះ នៅខណៈពេលដែលតុលាការត្រូវបានគេដឹងជាទូទៅថា មានការទទួលរងនូវឥទ្ធិពលពីអង្គការនីតិប្រតិបត្តិ។ ការចុះបញ្ជីមានសុពលភាពចាប់ពីថ្ងៃទទួលបានការយល់ព្រមមិនមែនថ្ងៃដាក់សំណុំលិខិតនោះទេ។ ហើយសេចក្តីព្រាងច្បាប់នេះ មិនបានចែងឲ្យបានជាក់លាក់ពីការដោះស្រាយនានាក្នុងករណី ដែលក្រសួងមហាផ្ទៃមិនមើលលើសំណុំលិខិត ឬបដិសេដមិនផ្តល់ ឬមិនព្រមទទួលចុះបញ្ជី។ សមាគមអង្គការដែលដាក់សំណុំលិខិតទាំងនោះ គឺមានជំរើសតែមួយគត់ គឺត្រូវតែរង់ចាំ។ លើសពីនេះទៅទៀត សេចក្តីព្រាងច្បាប់មិនបាននិយាយអ្វីឡើយទាក់ទងនឹងការកំណត់ថ្លៃបង់ប្រាក់ក្នុងការចុះបញ្ជី ឬ ការកំណត់នីតិក្រមនៃអង្គការមិនមែនរដ្ឋាភិបាល ដែលចង់បង្កើតសម្ព័ន្ធភាព។ ក៏ប៉ុន្តែសេចក្តីព្រាង

ច្បាប់នេះក៏មិនបានកំណត់នូវភាពជាក់លាក់ ដែលថានឹងមិនមានការយកថ្លៃលើការចុះបញ្ជី ឬក៏មានការកំណត់អោយយកថ្លៃក្នុងការចុះបញ្ជីដែរ។ ភាពខ្វះចន្លោះបែបនេះ និងចំនុចដែលមិនបាននិយាយលំអិត ជាការពិតនឹងត្រូវកំណត់ដោយបញ្ញត្តិច្បាប់ផ្សេងទៀតដូចជាអនុក្រិត្យជាដើម ដែលនេះ គឺជាការបង្កើតឡើងដោយមិនមានតម្លាភាព។ នេះអាចធ្វើឲ្យមានការបាត់បង់ឱកាសដល់អ្នកពាក់ព័ន្ធមួយចំនួន ក្នុងការចូលរួមពិគ្រោះយោបល់ឲ្យបានលទ្ធផលវិជ្ជមានលើសេចក្តីព្រាងច្បាប់នេះ។

របាយការណ៍សង្ខេបនេះ ផ្តោតលើគុណវិបត្តិដ៏ធ្ងន់ធ្ងរបំផុតនៃសេចក្តីព្រាងច្បាប់នេះ ដែលបណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា (CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) បានចែកជា៤ចំណុចសំខាន់ៗគឺ:

(១) ការរឹតបន្តឹងទៅលើសិទ្ធិចូលរួមជាសមាគមដោយសេរី
(២) ការដាក់បន្ទុកនៃតម្រូវការនៃការចុះបញ្ជីសម្រាប់អង្គការសមាគមមួយចំនួន
(៣)ការផ្តល់អំណាចយ៉ាងច្រើនលើសលប់ដល់មន្ត្រីរដ្ឋាភិបាលនៃស្ថាប័ននីតិប្រត្តិបត្តិ
(៤) ការរឹតត្បិតមិនសមរម្យលើអង្គការមិនមែនរដ្ឋាភិបាលបរទេស។

ជារួមទោះបីជាបណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា (CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ទទួលស្គាល់ថា សេចក្តីព្រាងច្បាប់លើកទី៤ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានចំណុចល្អប្រសើរគួរឲ្យកត់សម្គាល់មួយចំនួនខ្លះៗក៏ដោយ ក៏អង្គការទាំងអស់នោះយល់ឃើញថា សេចក្តីពង្រាងច្បាប់នេះគួរតែមិនត្រូវបានអនុម័តទេ។ សំណួរទាក់ទងទៅនឹងភាពចាំបាច់នៃច្បាប់ (និងចេតនារបស់រដ្ឋាភិបាល) នៅតែមាន។

## ២. ការវិភាគលើសេចក្តីព្រាងច្បាប់លើកទី៤

របាយការណ៍នេះ មិនមានគោលបំណងដើម្បីផ្តល់នូវការវិភាគតាមមាត្រាមួយៗនៃសេចក្តីព្រាងច្បាប់នេះទេ ប៉ុន្តែដើម្បីលើកឡើងនូវចំណុចអវិជ្ជមានមួយចំនួននៅក្នុងសេចក្តីព្រាងច្បាប់នេះ ដែលនឹងមានផលប៉ះពាល់លើឯករាជភាពរបស់សង្គមស៊ីវិលក្នុងប្រទេសកម្ពុជា។

### ការរឹតបន្តឹងទៅលើសិទ្ធិចូលរួមជាសមាគមដោយសេរី

ផ្នែកដែលគួរឲ្យចាប់អារម្មណ៍ក្នុងសេចក្តីព្រាងច្បាប់មុនៗ (ការតម្រូវឲ្យមានការចុះបញ្ជីសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល) ត្រូវបានលុបចេញពីសេចក្តីព្រាងច្បាប់ទី៤។ ក៏ប៉ុន្តែ ការលុបចោលនេះ គឺមានតែឈ្មោះប៉ុណ្ណោះទេ។ ការចុះបញ្ជីនៅតែជាលក្ខខណ្ឌសម្រាប់ក្រុមអង្គការសមាគមភាគច្រើន។ ក្នុងផ្នែកខ្លះ ការតម្រូវឲ្យចុះបញ្ជីនេះចាត់ទុកថាសមហេតុសមផលប៉ុន្តែនៅក្នុងផ្នែកដទៃទៀតគឺមិនអាចទទួលយកបានឡើយ។

នៅក្នុងមាត្រា ៥ នៃសេចក្តីព្រាងច្បាប់នេះបានចែងថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចបង្កើតឡើង ដោយសេរីមិនចាំបាច់មានការអនុញ្ញាត ឬការជូនដំណឹងជាមុនឡើយ ប៉ុន្តែសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងនោះនឹងមិនទទួលបានសមត្ថភាពតាមផ្លូវច្បាប់ទេ លុះត្រាតែខ្លួនបានបំពេញតាមបទបញ្ញត្តិដូចមានចែងក្នុងមាត្រា ៧នៃច្បាប់នេះ។

ប្រយោគនៅក្នុងបទបញ្ញត្តិនេះ បង្កប់នូវចម្ងល់ជាច្រើនដូចជា៖ តើសមត្ថភាពតាមផ្លូវច្បាប់ មានន័យយ៉ាងដូចម្តេចនៅក្នុងបរិបទនេះ? តើក្នុងស្ថានភាពមួយណាដែលគេត្រូវការសមត្ថភាពតាមផ្លូវច្បាប់នេះ? តើនឹងមានអ្វីកើតឡើងប្រសិនបើអង្គការមួយធ្វើសកម្មភាពដោយមិនមានសមត្ថភាពតាមផ្លូវច្បាប់?

សមត្ថភាពតាមផ្លូវច្បាប់ មិនត្រូវបានឲ្យនិយមន័យនៅក្នុងសេចក្តីព្រាងច្បាប់នេះឡើយ ប៉ុន្តែពាក្យនេះ ត្រូវបានសន្មត់ថាសំដៅទៅលើការបង្កើតនីតិបុគ្គលស្របច្បាប់។ សមត្ថភាពតាមផ្លូវច្បាប់នេះ អនុញ្ញាតឲ្យបុគ្គលិកនៅក្នុងអង្គការមួយធ្វើសកម្មភាពក្នុងនាមអង្គការនោះ មិនមែនក្នុងនាមរបស់ខ្លួនគេផ្ទាល់នោះទេ។ បញ្ញត្តិនានានៅក្នុងសេចក្តីព្រាងច្បាប់នេះបានផ្តល់នូវសញ្ញាណខ្លះអំពីថា តើសមត្ថភាពតាមផ្លូវច្បាប់សំដៅលើអ្វី? ហើយនរណាត្រូវការសមត្ថភាពតាមផ្លូវច្បាប់នេះ។ ឧទាហរណ៍ មាត្រា ២១-២៣ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចស្នើសុំនាំចូលសម្ភារៈគ្រឿងបរិក្ខារចាំបាច់សម្រាប់ប្រើប្រាស់ស្របតាមគម្រោងជំនួយរបស់ខ្លួនដោយពន្ធ និងអាករលើការនាំចូលជាបន្ទុករបស់រដ្ឋ។ មានសិទ្ធិជ្រើសរើសបុគ្គលិក និងអាចចុះកិច្ចសន្យា។

បណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា (CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ជឿជាក់ថាតម្រូវការឲ្យមានសមត្ថភាពតាមផ្លូវច្បាប់គឺអាចយល់ និងទទួលយកបានសម្រាប់សមាគមមួយចំនួន និងអង្គការមិនមែនរដ្ឋាភិបាលភាគច្រើន។ ជាទូទៅ អង្គការសមាគមទាំងនេះ ត្រូវការសមត្ថភាពតាមផ្លូវច្បាប់ដើម្បីជួលអគារចុះកិច្ចសន្យាជាមួយបុគ្គលិក បើកគណនីធនាគារ ចុះកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ តំណាងពួកគេជានីតិបុគ្គល។ល។ ជម្រើសមួយចំពោះសមត្ថភាពតាមផ្លូវច្បាប់នេះ គឺដើម្បីឲ្យបុគ្គលិកម្នាក់ៗធ្វើសកម្មភាពទាំងនេះក្នុងនាមឈ្មោះរបស់ខ្លួនផ្ទាល់។

ក៏ប៉ុន្តែ ការមិនព្រមចុះបញ្ជីរបស់ក្រសួងមហាផ្ទៃដល់អង្គការមួយចំនួននោះ បានបង្ហាញច្បាស់លាស់ថា ជាការផ្តល់នូវផលអវិជ្ជមាននូវសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន។ ប្រសិនបើមិនមានភាពស្របច្បាប់ទេ អង្គការមិនមែនរដ្ឋាភិបាលមួយមិនអាចទទួលបាននូវផលប្រយោជន៍ដូចដែលបានចែងក្នុងមាត្រា ២១-២៣ ហើយនឹងមិនអាចមានសិទ្ធិក្នុងការចុះកិច្ចសន្យា ចុះកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ ជួលបុគ្គលិក ជួលអគារ និងតំណាងខ្លួនឯងជាអង្គភាពមួយ។ អង្គការទាំងនោះអាចប្រឈមមុខនឹងការផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌ ដែលនឹងលំអិតខាងក្រោម។

ដោយហេតុផលនេះហើយ ជាការចាំបាច់ណាស់ថា នីតិវិធីនៃការចុះបញ្ជីគួរតែធ្វើឲ្យទៅជាងាយស្រួលបំផុត អព្យាក្រឹត ត្រឹមត្រូវប្រកបដោយយុត្តិធម៌ និងមិនប្រកាន់បក្សនយោបាយ។ បើនិយាយសរុបមក ដូច្នេះការចុះបញ្ជីនេះគួរតែ "ជាការបង្គ្រប់កិច្ចតែប៉ុណ្ណោះ"។ បញ្ហានេះ នៅតែមាននៅក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះ ហើយនឹងត្រូវបានពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងផ្នែក "ការផ្តល់អំណាចលើសលុបដល់មន្ត្រីរដ្ឋាភិបាលនៅក្នុងស្ថាប័ននីតិប្រតិបត្តិ"។

### *ចំណាប់អារម្មណ៍រួមរបស់សមាគម ក្រុមក្រៅផ្លូវការ និងបណ្តាញ៖ តើពួកគេនឹងចូលទៅក្រុមណាមួយ?*

ខណៈពេល ដែលភាពចាំបាច់នៃការចុះបញ្ជីមានភាពច្បាស់លាស់សម្រាប់អង្គការធំៗដែលទាមទារឲ្យមានសមត្ថភាពតាមផ្លូវច្បាប់ បញ្ហាគឺនៅតែមិនច្បាស់លាស់សម្រាប់សមាគមតូចៗ ក្រុមក្រៅផ្លូវការ និងបណ្តាញ។

ក្រុមទាំងនោះ អាចជាក្រុមក្រៅផ្លូវការតូច និងបណ្តោះអាសន្ន ហើយប្រហែលជាអ្នកទាំងនោះមិនចាំបាច់ទទួលនូវសមត្ថភាពតាមផ្លូវច្បាប់ដើម្បីជួលបុគ្គលិក ចុះហត្ថលេខា

ជួលផ្ទះ នាំសម្ភារៈចូល ។ល។ និង។ល។ តើមានអ្វីកើតឡើងប្រសិនបើក្រុមអង្គការទាំងនេះមិនចុះបញ្ជី?

ច្បាប់នេះ ផ្តោតលើក្រុមទី៣ សម្រាប់អង្គការទាំងនេះ គេហៅថា អង្គការសហគមន៍មូលដ្ឋានដែលត្រូវបានឲ្យនិយមន័យនៅក្នុងមាត្រា៤ និងមាត្រា៥។ ប៉ុន្តែក្រុមនេះ គឺមានលក្ខណៈមិនទូលំទូលាយ ដែលមិនបានរាប់បញ្ចូលក្រុមដែលមានស្រាប់ និងកំពុងដំណើរការជាច្រើនក្នុងប្រទេសកម្ពុជា។

មាត្រា ៤ ឲ្យនិយមន័យអង្គការនេះ ថា ជា"ក្រុមប្រជាពលរដ្ឋដែលស្ម័គ្រចិត្តរួមគ្នាបង្កើតគ្រប់គ្រង និងធ្វើសកម្មភាពដោយខ្លួនឯង ដើម្បីបម្រើ និងការពារផលប្រយោជន៍ក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន"។ មាត្រា៥ ចែងថា "អង្គការសហគមន៍មូលដ្ឋាន មិនតម្រូវឲ្យចុះបញ្ជីតាមបទបញ្ញត្តិនៃច្បាប់នេះឡើយ លើកលែងតែមានការកំណត់តាមបទបញ្ញត្តិនៃច្បាប់ដោយឡែក ប៉ុន្តែអង្គការសហគមន៍មូលដ្ឋានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីឈ្មោះរបស់អង្គការ វត្ថុបំណង និងឈ្មោះរបស់ប្រធានអង្គការទៅអាជ្ញាធរឃុំ ឬសង្កាត់ដែលខ្លួនធ្វើសកម្មភាព"។[២]

សេចក្តីព្រាងច្បាប់នេះ មិនបានពន្យល់ឲ្យបានច្បាស់លាស់អំពីនិយមន័យ "សហគមន៍មូលដ្ឋាន" ប៉ុន្តែ មានបញ្ញត្តិផ្សេងទៀតហាក់ដូចជាដាក់ព្រំដែនកំណត់ដល់អង្គការសហគមន៍មូលដ្ឋានក្នុងការអនុវត្តសកម្មភាពនៅក្នុងឃុំ ឬសង្កាត់របស់អ្នកទាំងអស់នោះតែប៉ុណ្ណោះ។[៣]

ការដាក់កំហិតអាចមិនមែនជាឧបសគ្គសម្រាប់ក្រុមខ្លះ ប៉ុន្តែជាក់ស្តែងអង្គការជាច្រើនមិនរឹតត្បិតខ្លួនលើខណ្ឌសីមានៃឃុំរបស់អ្នកទាំងនោះឡើយ។ អ្នកទាំងអស់នោះ អាចធ្វើសកម្មភាពច្រើនខេត្តដូចជា បណ្តាញព្រៃឡង់ ដែលបានឲ្យនិយមន័យថា "សហគមន៍" ដែលមានតំបន់ព្រៃធំក្របដណ្តប់លើខេត្តចំនួន៤។

[២] FNN, CCFC, IDEA, CYN and LICADHO ជឿថា ការជូនដំណឹងនេះ គឺជាការរំលោភបំពានដ៏អាក្រក់មួយទៅលើសិទ្ធិសេរីភាពក្នុងការចូលរួមជាសមាគម ហើយនឹងទំនងត្រូវបានយកទៅប្រើជាដំណើរការ "ស្នើសុំច្បាប់អនុញ្ញាត"យ៉ាងជាក់លាក់មួយ។ ខចែងនេះបដិសេធយ៉ាងពិតប្រាកដចំពោះក្រុមសហគមន៍អំពីលទ្ធភាពក្នុងការរៀបចំ និងការប្រព្រឹត្តិទៅដោយពុំមានការគ្រោងទុក។ ក្រុមនេះជំរុញឲ្យមានការលុបចោល ខចែងនេះចេញពីសេចក្តីព្រាងច្បាប់នេះ។

[៣] ច្បាប់នេះមានអត្ថន័យថា អង្គការមិនមែនរដ្ឋាភិបាល និងសមាគម គឺជាក្រុមដែលបង្កើតឡើងដើម្បី"ធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ" ខណៈដែលអង្គការដែលមានមូលដ្ឋានក្នុងសហគមន៍ ត្រូវបានដាក់កំហិតទៅលើសកម្មភាព"ផ្តល់សេវាកម្ម និងការពារផលប្រយោជន៍ក្នុងសហគមតាមមូលដ្ឋានរបស់ខ្លួន" (មាត្រា ៤) ។ នេះ គឺជាការរំលោភបំពានមួយយ៉ាងជាក់លាក់ទៅលើមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ដែលផ្តល់សិទ្ធិឲ្យពលរដ្ឋខ្មែរចូលរួមយ៉ាងសកម្មក្នុងកិច្ចការនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌" របស់ប្រទេសជាតិ" ដូចជានៅកំរិតថ្នាក់ជាតិជាដើម ។

ក្រុមផ្សេងទៀតអាចចូលរួមជាមួយបណ្តាញសកម្មជនមូលដ្ឋាន។ ប៉ុន្តែសេចក្តីព្រាងច្បាប់ នេះ ទំនងជាតម្រូវឲ្យក្រុមទាំងនោះ ធ្វើសកម្មភាពតែនៅក្នុងឃុំរបស់អ្នកទាំងនោះតែប៉ុណ្ណោះទេ។

តើមានអ្វីកើតឡើង ប្រសិនបើអង្គការសហគមន៍មូលដ្ឋានធ្វើសកម្មភាពក្រៅតំបន់ដែលគេយល់ព្រម? តើអ្នកទាំងនោះនៅតែជាអង្គការសហគមន៍មូលដ្ឋានឬទេ? តើអ្នកនោះនឹងក្លាយទៅជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលឬទេ? តើពួកគេនឹងតម្រូវឲ្យចុះបញ្ជីដែរឬទេ? តើពួកគេ "ខុសច្បាប់ទេ" ប្រសិនបើមិនបានចុះបញ្ជី។

សំណួរនេះ មិនមែនគ្រាន់តែជាទ្រឹស្តីទេ។ ទោះបីជាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលពុំមានបញ្ញត្តិនៃការផ្តន្ទាទោសក៏ដោយ ក៏ប៉ុន្តែមានក្រមព្រហ្មទណ្ឌមានបញ្ញត្តិមួយចំនួន ដែលហាក់បីដូចជាការរៀបចំសម្រាប់ការផ្តន្ទាទោសដល់ក្រុមដែលមិនបានចុះបញ្ជី។ ច្បាប់ទាំងនេះ អាចត្រូវបានប្រើប្រាស់ដើម្បីដាក់ទោសដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណាដែលមិនបានចុះបញ្ជី។

មាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌ ចែងថា "ការឆបោក" គឺជាអំពើបន្លំ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឲ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬ របស់តតិយជននូវៈ (១)-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។ (២)- ការផ្តត់ផ្គង់សេវា។ (៣)- ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឲ្យរួចពីកាតព្វកិច្ច"។ ការក្លែងបន្លំអាចត្រូវបានផ្តន្ទាទោសរហូតដល់៣ឆ្នាំ។

មាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌចែងអំពី " "ការរំលោភលើទំនុកចិត្ត" គឺជាអំពើគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឲ្យខូចប្រយោជន៍អ្នកដទៃប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឲ្យបុគ្គលនោះ ហើយបុគ្គលនោះបាន យល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់" ។ ការក្លែងបន្លំអាចត្រូវបាន ផ្តន្ទាទោសរហូតដល់៣ឆ្នាំ។ ជាចុងបញ្ចប់មាត្រា៥៨៤ នៃក្រមព្រហ្មទណ្ឌចែងអំពី " "បទបំពានលើកាតព្វកិច្ច ដែលប្រកាសទៅលើនីតិបុគ្គល" កាលបើកាតព្វកិច្ច ឬការហាមឃាត់ត្រូវបានប្រកាសទៅលើនីតិបុគ្គល ការបំពានដោយរូបវន្តបុគ្គលដែលត្រូវអនុវត្តកាតព្វកិច្ច ឬការហាមឃាត់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០ (ពីរលាន) រៀល ទៅ៤,០០០,០០០ (បួនលាន) រៀល "។

ភាពគ្រោះថ្នាក់នៃសេចក្តីព្រាងច្បាប់នេះគឺមើលឃើញយ៉ាងច្បាស់។ រដ្ឋាភិបាលបាន លុបចោលនូវតម្រូវការនៃការចុះបញ្ជី នៅតែក្នុងឈ្មោះប៉ុណ្ណោះ ហើយទំនងដូចជាមិនមែន ជាចេតនាពិតប្រាកដរបស់លោកទេ។

បណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា (CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ជឿជាក់ ថា សេចក្តីព្រាងច្បាប់នេះគួរតែបញ្ជាក់បន្ថែមទៀតថាក្រុមមួយណាដែលតម្រូវឲ្យចុះបញ្ជី។ ជាពិសេសក្រុមអង្គការសហគមន៍មូលដ្ឋានគួរតែប្តូរឈ្មោះ និងពង្រីកវិសាលភាព ដើម្បី បន្ថែមក្រុមផ្សេងទៀត។ ការដាក់ដែនកំណត់ទៅតាមទំនើងចិត្ត លើក្រុមទាំងអស់នោះ (តម្រូវឲ្យអ្នកទាំងនោះនៅតែក្នុងឃុំ និងធ្វើសកម្មភាពបម្រើផលប្រយោជន៍ តែសហគមន៍ របស់អ្នកទាំងអស់នោះប៉ុណ្ណោះទេ) គួរតែលុបចោលពីសេចក្តីព្រាងច្បាប់នេះទៅ។ អង្គការ សហគមន៍មូលដ្ឋាន គួរតែត្រូវបានដាក់បញ្ចូលទៅក្នុងក្រុមក្រៅផ្លូវការដែលធ្វើសកម្មភាព ខាងក្រៅសហគមន៍មូលដ្ឋានរបស់អ្នកទាំងអស់នោះ និងអាចធ្វើសកម្មភាពដើម្បី "សារៈ ប្រយោជន៍សាធារណៈ"។

ការចុះបញ្ជីមិនគួរជាតម្រូវការចាំបាច់សម្រាប់ក្រុមទាំងនោះទេ ការផ្តល់ដំណឹងជូន ដល់អាជ្ញាធរក៏មិនគួរអនុវត្តដែរ។

### *ការចុះបញ្ជីឡើងវិញសម្រាប់អង្គការដែលស្រាប់ហើយនៅតែជាតម្រូវការចាំបាច់*

ច្បាប់នេះមានលក្ខណៈផ្ទុយលើតម្រូវការចាំបាច់ក្នុងការចុះបញ្ជី។ មាត្រា ៥ បាន ចែងថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចបង្កើតឡើងដោយសេរីមិនចាំបាច់ចុះ បញ្ជីឡើយ។ ប៉ុន្តែ មាត្រា៣២ តម្រូវឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក" ជូនដំណឹងជាលាយលក្ខណ៍អក្សរពីការបន្តសកម្មភាពរបស់ខ្លួនក្នុងរយៈពេល យ៉ាងយូរ ៣៦៥ ថ្ងៃ ដោយមានបញ្ជាក់អំពីឈ្មោះ អាសយដ្ឋាននៃទីស្នាក់ការ អត្តសញ្ញាណថ្នាក់ ដឹកនាំ និងលក្ខន្តិកៈកែប្រែចុងក្រោយ (បើមាន)។ បើហួសរយៈពេលដូចបានកំណត់ខាង លើនេះ ក្រសួងមហាផ្ទៃចាត់ទុកថា សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ បានបោះបង់សកម្មភាពរបស់ខ្លួនហើយ"។

អត្ថន័យនៃមាត្រា ៣២ គឺច្បាស់លាស់ថា ការចុះបញ្ជីឡើងវិញគឺជាតម្រូវការចាំបាច់ ទោះបីជាអង្គការដែលមិនចង់ទទួលបាននូវសមត្ថភាពតាមផ្លូវច្បាប់ក៏ដោយ។ នេះមិន ស្របតាមបញ្ញត្តិផ្សេងទៀតនៅក្នុងច្បាប់នេះឡើយ ហើយរំលោភបញ្ញត្តិច្បាប់អន្តរជាតិស្តី

ពីសិទ្ធិចូលរួមជាសមាគមដោយសេរី[៤]។ មាត្រា៣២ គួរតែបញ្ជាក់បន្ថែមថា ការចុះបញ្ជីឡើងវិញគឺចាំបាច់សម្រាប់តែអង្គការណាដែលចង់បានសមត្ថភាពផ្លូវច្បាប់។

## *តើសម្ព័ន្ធភាពគ្រប់គ្រងដោយច្បាប់នេះទេ?*

ចុងក្រោយ សេចក្តីព្រាងច្បាប់លើកទី៤ កាត់ចោលនូវផ្នែកចាស់ទាក់ទងនឹង "សម្ព័ន្ធ" របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ប៉ុន្តែមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ថាតើ "សម្ព័ន្ធ" នេះអនុញ្ញាតិឲ្យធ្វើដែរឬទេ (អតីតមាត្រា១៩ -២៧)។ ក៏ប៉ុន្តែសេចក្តីព្រាងច្បាប់នេះបានចែងថា សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលអាចត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬ "នីតិបុគ្គល"ទៅវិញ។

តើនេះមានន័យថា សម្ព័ន្ធភាពនឹងត្រូវចុះបញ្ជីខុសពីសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលដាច់ដោយឡែកដែរឬទេ? តើសម្ព័ន្ធភាពបែបនេះអនុញ្ញាត្តិឲ្យមានការបញ្ចូលគ្នារវាងអង្គការក្នុងស្រុក និងអង្គការបរទេសដែរឬទេ? ជាថ្មីម្តងទៀត សេចក្តីព្រាងច្បាប់នេះផ្តល់នូវសំណួរជាងចម្លើយ។

## **បន្ទុកនៃតម្រូវការ និងនីតិវិធីចុះបញ្ជី**

សេចក្តីព្រាងច្បាប់ថ្មីកាត់បន្ថយបន្ទុក នៃតម្រូវការចុះបញ្ជីបានល្អប្រសើរជាងសេចក្តីព្រាងច្បាប់មុនៗ ប៉ុន្តែ តម្រូវការនានានៅតែជាបញ្ហាសម្រាប់អង្គការជាច្រើន។ នេះគឺជាការពិតប្រាកដ ដោយសារតែកង្វះខាតនៃសេចក្តីព្រាងច្បាប់នេះ មិនបង្ហាញឲ្យបានច្បាស់លាស់ថាតើ ក្រុមណាត្រូវតែចុះបញ្ជី។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលមានទីស្នាក់ការនៅរាជធានីភ្នំពេញ និងមានដំណើរការច្បាស់លាស់រួចទៅហើយ (មានមេធាវី មន្ត្រីអនុវត្តច្បាប់ និងសមត្ថភាពក្នុងការបញ្ជូន និងពិនិត្យឡើងវិញលើការដាក់ពាក្យសុំចុះឈ្មោះ) អាចនឹងពុំមានការលំបាកខ្លាំងក្នុងការចុះបញ្ជីនោះទេ។ ប៉ុន្តែ មិនមែនជាចុងបញ្ចប់នៃការវិភាគឡើយ។ ដូចដែលបានបញ្ជាក់នៅខាងលើសេចក្តីព្រាងច្បាប់នេះ បង្កើតផ្នែកសំខាន់ៗបី ដែលទំនង

---

[៤] មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយធានាឲ្យមានសិទ្ធិសេរីភាពក្នុងការចូលរួមជាសមាគមដូចតទៅ៖

១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃរាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យក្នុង ផលប្រយោជន៍នៃសន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។ មាត្រានេះ មិនរារាំងដល់ការរិតត្បិតខាងផ្លូវច្បាប់លើសមាជិកយោធា និងនគរបាលក្នុងការប្រើប្រាស់សិទ្ធិនេះទេ។

បង្វែរទិសស្ទើរតែគ្រប់នីតិបុគ្គលមិនរកប្រាក់ចំណេញ ដែលអាចនឹងបង្កើតនៅក្នុងប្រទេសកម្ពុជា។[៥] នេះមានន័យថា អង្គការតូចៗជាច្រើន រួមទាំងក្រុមក្រៅផ្លូវការ និងក្រុមសមាជិកភាពនឹងត្រូវបង្ខំឲ្យចុះបញ្ជី។ បើដូចនេះមែន អង្គការ និងក្រុមទាំងនោះ អាចមានការលំបាកក្នុងការអនុវត្តទៅតាមតម្រូវការចុះបញ្ជី។

ឧទាហរណ៍ ដើម្បីទទួលបានការចុះបញ្ជី ក្រុមទាំងអស់ត្រូវតែបញ្ជូនលក្ខន្តិកៈ អង្គការដែលអនុលោមទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់មានស្រាប់ដទៃទៀត ដែលគ្របដណ្តប់លើចំណុចជាក់លាក់នានាដូចជា៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ វិធាននៃការជ្រើសរើសនាយក វិធាននៃការធ្វើវិសោធនកម្មលក្ខន្តិកៈ ប្រភពធនធាន និងទ្រព្យសម្បត្តិ ។ល។ និង។ល។ ការទាមទារទាំងនេះមិនមែនជាបន្ទុកដ៏ធ្ងន់ធ្ងរណាស់ណាសម្រាប់អង្គការធំៗទេ ប៉ុន្តែ មានការលំបាក និងមិនចាំបាច់ដល់បណ្តាញកសិករ ឬក្រុមក្រៅផ្លូវការ ឬសកម្មជនព្រៃឈើទេ។

បណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា (CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ជឿជាក់ថាបញ្ហាទាំងនេះអាចត្រូវបានដោះស្រាយ ប្រសិនបើសេចក្តីព្រាងច្បាប់នេះធ្វើសេចក្តីបញ្ជាក់បន្ថែមថា តើក្រុមណាខ្លះតម្រូវឲ្យធ្វើការចុះបញ្ជីដូចដែលបានបញ្ជាក់នៅផ្នែកមុន។ ជាពិសេសក្រុមអង្គការសហគមន៍មូលដ្ឋាន គួរតែត្រូវបានប្តូរឈ្មោះ និងពង្រីកបន្ថែមដើម្បីទទួលបានក្រុមបន្ថែមទៀត ហើយមិនចាំបាច់ចុះបញ្ជី និងផ្តល់ដំណឹងដល់អាជ្ញាធរឡើយ។

## ការផ្តល់អំណាចយ៉ាងច្រើនលើសលុបដល់មន្ត្រីរដ្ឋាភិបាលនៃស្ថាប័ននីតិប្រត្តិបត្តិ

សេចក្តីព្រាងច្បាប់លើកទី៤ នៅតែមានបញ្ញត្តិ ដែលផ្តល់អំណាចលើសលុបដល់ក្រសួងនានា ដែលមានតួនាទីក្នុងការចុះបញ្ជី។ បញ្ហានេះ ត្រូវបានពិភាក្សាចំនួនបីលើកយ៉ាងទូលំទូលាយក្នុងរបាយការណ៍សង្ខេបមុនរបស់អង្គការ លីកាដូ ហើយមិនទាន់ត្រូវបានដោះស្រាយនៅក្នុងសេចក្តីព្រាងច្បាប់លើកទី៤ទេ។

---

[៥] អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវបានគេផ្តល់និយមន័យថា ជាក្រុមមនុស្សដែលមានសញ្ជាតិខ្មែរ ឬជាស្ថាប័នស្របច្បាប់ ដែលយល់ព្រមបង្កើតឡើងដើម្បីធ្វើសកម្មភាពនានាក្នុងគោលបំណងបម្រើផលប្រយោជន៍សាធារណៈ ដោយមិនធ្វើសកម្មភាពណាដែលស្វែងរកប្រាក់ចំណេញសម្រាប់ចែករំលែកដល់សមាជិករបស់ខ្លួនទេ (មាត្រា៤) ។ សមាគមក្នុងស្រុក គឺជាក្រុមមនុស្សដែលមានសញ្ជាតិខ្មែរ ឬជាស្ថាប័នស្របច្បាប់ ដែលយល់ព្រមបង្កើតឡើងសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួនដោយមិនធ្វើសកម្មភាពណាមួយដើម្បីស្វែងរកប្រាក់ចំណេញសម្រាប់ចែកដល់សមាជិករបស់ខ្លួនទេ។ សមាគមក្នុងស្រុក ក៏អាចធ្វើសកម្មភាពសម្រាប់បម្រើផលប្រយោជន៍សាធារណៈដែរ" (មាត្រា៤)។

សេចក្តីព្រាងច្បាប់នេះ នៅតែមិនមាននីតិវិធីប្តឹងតាមផ្នែករដ្ឋបាលចំពោះការមិនព្រមទទួលការចុះបញ្ជីនៅក្នុងមាត្រា៨។ ជំនួសមកវិញ អង្គការមិនមែនរដ្ឋាភិបាលដែលមានសំណុំលិខិតចុះបញ្ជីត្រូវបានបដិសេធនោះ ត្រូវតែប្តឹងតុលាការនេះ ជាមធ្យោបាយមួយដែលអាចធ្វើឲ្យមានការយឺតយាវ និងអាចមានឥទ្ធិពលពីស្ថាប័ននីតិប្រតិបត្តិ។

ក្នុងមាត្រា៧ នៅតែមានការខ្វះខាតគោលការណ៍ណែនាំ នៃការយល់ព្រមទទួលយកការចុះបញ្ជី។ សេចក្តីព្រាងច្បាប់នេះ ផ្តល់អំណាចដល់ក្រសួងមហាផ្ទៃស្របតាមវិធានបទទាក់ទងនឹងរដ្ឋធម្មនុញ្ញ ឬតាមផ្លូវច្បាប់នៃការដាក់ពាក្យសុំចុះឈ្មោះរបស់អង្គការមិនមែនរដ្ឋាភិបាល។ មធ្យោបាយនេះនឹងអាចផ្តល់ឲ្យក្រសួងមហាផ្ទៃអាចរំលោភបំពាន និងផ្តល់នូវអំណាចយុត្តិធម៌ និងរដ្ឋធម្មនុញ្ញ ដែលមិនស័ក្តិសមសម្រាប់ប្រទេសមួយ ដែលបានអះអាងថាគោរពលើការបែងចែកអំណាចផ្សេងៗគ្នា។ សេចក្តីព្រាងច្បាប់នេះ គួរតែបញ្ជាក់ឲ្យបានច្បាស់លាស់ថា ក្រសួងមហាផ្ទៃអាចសម្រេចមិនព្រមទទួលចុះបញ្ជីបានប្រសិនបើសំណុំលិខិតមិនពេញលេញ និងមិនបានបញ្ជូនមក។

បញ្ហានេះ គឺសំខាន់ណាស់ពីព្រោះការមិនទទួលចុះបញ្ជីរបស់ក្រសួងមហាផ្ទៃនឹងដកហូតនូវសមត្ថភាពប្រតិបត្តការរបស់អង្គការមិនមែនរដ្ឋាភិបាល។ ដូចដែលបានបញ្ជាក់ខាងលើ អង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះឈ្មោះពុំមានសមត្ថភាពផ្លូវច្បាប់ទេ និងមិនអាចចុះលើកិច្ចសន្យា កិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ ជ្រើសរើសបុគ្គលិកតំណាងជាអង្គការមួយ ។ល។ និង ។ល។ បុគ្គលិក ឬសមាជិកអង្គការបែបនេះនឹងអាចប្រឈមមុខការចោទប្រកាន់នានាតាមក្រមព្រហ្មទណ្ឌ។

ដោយហេតុផលបែបនេះ ជាការសំខាន់ដែលគុណវិបត្តិនៃនីតិវិធីចុះបញ្ជីគួរតែត្រូវបានយកមកដោះស្រាយ។ នីតិវិធីត្រូវតែងាយស្រួល អព្យាក្រឹត ត្រឹមត្រូវ និងយុត្តិធម៌ និងមិនប្រកាន់បក្សនយោបាយ។

សេចក្តីព្រាងច្បាប់នេះ ក៏មានចន្លោះប្រហោងដែលអនុញ្ញាតឲ្យក្រសួងមហាផ្ទៃពន្យាពេលយ៉ាងយូរ។ អង្គការដាក់សំណុំលិខិតចុះបញ្ជីអាចប្តឹងបានតែការជំទាស់ពីការបដិសេធ ប៉ុន្តែពុំមានមធ្យោបាយនឹងតវ៉ា ប្រសិនបើ ក្រសួងមហាផ្ទៃមិនអនុវត្ត។ ក្រសួងមហាផ្ទៃពិនិត្យសំណុំលិខិតក្នុងរយៈ៤៥ថ្ងៃ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ថាតើត្រូវធ្វើយ៉ាងណា ប្រសិនបើនីតិវិធីនេះចំណាយពេលយូរជាង៤៥ថ្ងៃ។ ចម្ងល់នៅតែមានថា តើនៅពេលណារយៈ៤៥ថ្ងៃ ចាប់ផ្តើមរាប់ (ចាប់ពីថ្ងៃដាក់សំណុំលិខិត ឬចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃពិនិត្យលើសំណុំលិខិតនោះ)? ជាថ្មីម្តងទៀត សេចក្តីព្រាងច្បាប់នេះមិនបានបញ្ជាក់ពីចំណុចនេះឡើយ។

ទោះបីជាសំណុំលិខិតចុះឈ្មោះមិនត្រូវបានបដិសេធទាំងស្រុងក៏ដោយ ក៏មន្ត្រីខ្លះអាចនៅតែអះអាងថា មិនបានបំពេញលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌជាច្រើន ដែលបង្កឲ្យមានការពន្យាពេល ដែលអាចជាការគំរាមកំហែង និងអាចរារាំងអង្គការមួយចំនួនក្នុងការបន្តសំណុំលិខិតចុះឈ្មោះរបស់អ្នកទាំងអស់នោះទេ។ ជាពិសេសកើតមានចំពោះសមាគម និងអង្គការ ដែលមានមូលដ្ឋានតាមបណ្តាខេត្ត ដែលមិនមានមធ្យោបាយធ្វើដំណើរមកភ្នំពេញញឹកញាប់។ មន្ត្រីទាំងនោះអាចធ្វើបែបនេះ មិនគ្រាន់តែជាហេតុផលនយោបាយនោះទេ អាចសំដៅទៅអង្គការដែលរដ្ឋាភិបាលមិនពេញចិត្ត ឬក៏អាចទាញការយកប្រាក់កំរៃពីអង្គការដែលដាក់សំណុំលិខិតចុះឈ្មោះនោះដែរ។

បណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា (CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) ជឿជាក់ថា បញ្ហានេះអាចត្រូវបានយកដោះស្រាយមួយចំណែក ដោយការធ្វើឲ្យសំណុំលិខិតចុះបញ្ជី មានប្រសិទ្ធិភាពចាប់ពីថ្ងៃដាក់ពាក្យស្នើសុំទៅ មិនមែនចាប់ពីថ្ងៃទទួលការយល់ព្រមពីក្រសួងមហាផ្ទៃនោះទេ ដូចដែលបានចែងក្នុងមាត្រា៩។ ជាជម្រើស ប្រសិនបើក្រសួងមហាផ្ទៃខកខានមិនបានពិនិត្យសំណុំលិខិតក្នុងរយៈពេល ៤៥ថ្ងៃ នៃថ្ងៃដាក់សំណុំលិខិតនោះ មានន័យថា សំណុំលិខិតនោះត្រូវបានទទួលការព្រមចុះបញ្ជីដោយស្វ័យប្រវត្តិ។ ការផ្តល់សេចក្តីយល់ព្រមបែបនេះ មាននៅក្នុងច្បាប់របស់ប្រទេសកម្ពុជាឯទៀតដូចជា ច្បាប់ ស្តីពីការជួបប្រជុំដោយសន្តិវិធីជាដើម។

## ការរឹតបន្តឹងលើអង្គការមិនមែនរដ្ឋាភិបាលបរទេស

អង្គការមិនមែនរដ្ឋាភិបាលបរទេសប្រឈមមុខនឹងការរឹតត្បិតជាងមុន នៅក្នុងសេចក្តីព្រាងច្បាប់ចុងក្រោយនេះ។ បញ្ញត្តិទាំងអស់ គឺបញ្ជាក់យ៉ាងច្បាស់ថា រដ្ឋាភិបាលពេញចិត្តតែអង្គការមិនមែនរដ្ឋាភិបាលបរទេសណា ដែលផ្តល់មូលនិធិលើគម្រោងអភិវឌ្ឍផ្តោតសំខាន់លើការផ្តល់សេវាកម្ម។ ទោះបីជា មិនបង្ហាញដោយពាក្យចំៗ ប៉ុន្តែអង្គការបរទេសណាដែលធ្វើការលើការតស៊ូមតិ ឬកិច្ចការសិទ្ធិមនុស្សនឹងមិនដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់នេះទេ។

មុនដំបូងគ្រប់អង្គការមិនមែនរដ្ឋាភិបាលបរទេស និងសមាគមបរទេសទាំងអស់តម្រូវឲ្យបើកកិច្ចពិភាក្សា និងយល់ព្រមទៅលើស្ថាប័នជាដៃគូរបស់រដ្ឋាភិបាលស្តីពី "គម្រោង និងកម្មវិធីផ្តល់ជំនួយ" មុននឹងដាក់ពាក្យស្នើសុំអនុស្សរណៈយោគយល់គ្នា (MOU) (សូមមើលមាត្រា ១៤) ។ ឃ្លាសរសេរថា "គម្រោងផ្តល់ជំនួយ" មានការប្រើប្រាស់ជាបន្តបន្ទាប់ក្នុងសេចក្តីព្រាងច្បាប់នេះ ដែលអាចឲ្យយល់បានថា អង្គការមិនមែនរដ្ឋា

ភិបាលបរទេសណាដែលមិនផ្តល់ជំនួយជាសាច់ប្រាក់ សម្ភារៈ ឬក៏ហេដ្ឋារចនាសម្ព័ន្ធនោះ មិនអាចទទួលការស្វាគមន៍ឡើយ។ ក្នុងមាត្រា ១៥ បង្ហាញពីសញ្ញាដែលតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលបរទេសមិនត្រូវចំណាយលើសពី២៥ភាគរយ នៃថវិកាសរុបទៅលើកិច្ចការរដ្ឋបាលរួមទាំងប្រាក់ខែរបស់បុគ្គលិក ឧបករណ៍ការិយាល័យ និងការចំណាយផ្សេងៗទៀតសម្រាប់ធ្វើឲ្យការិយាល័យមានដំណើរការ។ នេះមិនរាប់បញ្ចូលចំពោះអង្គការមិនមែនរដ្ឋាភិបាលណា ដែលធ្វើការងារទាក់ទងជាសំខាន់ទៅលើការឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ការងារតស៊ូមតិ និងការបណ្តុះបណ្តាល។ គម្រោងខ្លះ បុគ្គលិកនោះឯងគឺជា "ជំនួយ"។

ជាពិសេស អង្គការមិនមែនរដ្ឋាភិបាលបរទេសក៏កំពុងប្រឈមនឹងទោសព្រហ្មទណ្ឌធ្ងន់ជាងមុន នៅក្នុងបទបញ្ញត្តិដូចតទៅនេះ៖

- មាត្រា ១២ តម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលបរទេសនឹងប្រគល់លិខិតប្រកាសគណនីធនាគាររបស់ខ្លួន ដែលបានផ្ញើនៅធនាគារយ៉ាងយូរ៣០ (សាមសិបថ្ងៃ) នៅថ្ងៃធ្វើការបន្ទាប់ពីបានចុះអនុស្សរណៈ។
- មាត្រា ១៧ បានអះអាងថា អាចបញ្ចប់សុពលភាពអនុស្សរណៈ ក្នុងករណីដែលសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬ បង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណីទំនៀមទំលាប់សង្គមជាតិកម្ពុជា។ ខ្លឹមសារនេះ មានលក្ខណៈមិនច្បាស់លាស់ដែលអនុញ្ញាតឲ្យបញ្ឈប់ទាំងស្រុងតាមអំពើចិត្ត នូវសកម្មភាពការងាររបស់អង្គការមិនមែនរដ្ឋាភិបាលជាពិសេសការផ្តល់អំណាចទាំងស្រុង។ ការបកស្រាយរបស់រដ្ឋាភិបាលពីអតីត កាលពីពាក្យពេចន៍ដូចខាងលើ និងការងារតស៊ូមតិ ដែលប៉ះពាល់ដល់រដ្ឋាភិបាលអាចចាត់ទុកថាជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ ឬរំលោភបទបញ្ញត្តិមាត្រា១៧នេះ។
- មាត្រា ៣១ អនុញ្ញាតឲ្យរដ្ឋាភិបាលរំលាយចោលអនុស្សរណៈយោគយល់គ្នាជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលបរទេស បើសិនអង្គការទាំងនោះ មិនបានអនុវត្តតាមតម្រូវការចាំបាច់ឲ្យផ្តល់របាយការណ៍ពិតប្រាកដ។ ផ្ទុយមកវិញ អង្គការក្នុងស្រុកនានាគ្រាន់តែលុបឈ្មោះចេញពីបញ្ជីចុះឈ្មោះប៉ុណ្ណោះ។
- មាត្រា ១៣ មិនតម្រូវឲ្យរដ្ឋាភិបាលផ្តល់ការពន្យល់ណាមួយដល់អង្គការមិនមែនរដ្ឋាភិបាលបរទេស ប្រសិនបើរដ្ឋាភិបាលបដិសេធចំពោះការដាក់ពាក្យស្នើសុំឲ្យមានអនុស្សរណៈ។ អង្គការមិនមែនរដ្ឋាភិបាលបរទេស ក៏ពុំមានសិទ្ធិក្នុងការកែប្រែការដាក់ពាក្យសុំ ឬប្តឹងតវ៉ាចំពោះការបដិសេធនោះទេ។

បណ្តាញកសិករ និងធម្មជាតិ (FNN) សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បណ្តាញយុវជនកម្ពុជា (CYN) និងអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) មានជំនឿថា បទបញ្ញត្តិនេះ អាចបង្កក្នុងការបង្កើតអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្ររដ្ឋាភិបាល។ នេះផ្ទុយគ្នាស្រឡះទៅនឹងនិយមន័យនៃពាក្យអង្គការមិនមែនរដ្ឋាភិបាល។ បទបញ្ញត្តិមិនត្រឹមត្រូវនេះ គួរតែធ្វើវិសោធនកម្ម ឬ ដកចេញតែម្តងដើម្បីអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលបរទេស មានសេរីភាពធ្វើប្រតិបត្តិការ និងមានការគ្រប់គ្រងតិចតួចពីសំណាក់រដ្ឋាភិបាល។[៦]

សេចក្តីព្រាងច្បាប់ទី៤ ក៏ផ្តោតទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលជ្រើសរើសបុគ្គលិកបរទេស។ មាត្រា២៣ បានចែងថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬ ចុះអនុស្សរណៈមានសិទ្ធិជ្រើសរើសបុគ្គលិក ឬកម្មករខ្មែរដើម្បីបំរើការងារ ។ ការជ្រើសរើសនេះ ត្រូវអនុវត្តតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា នឹងត្រូវជ្រើសរើសបុគ្គលិក ឬ កម្មករខ្មែរឲ្យបានច្រើនជាអតិបរមា។ អត្ថន័យពិតប្រាកដក្នុងមាត្រានេះគឺ មិនច្បាស់លាស់ ដូច្នេះភាពមិនច្បាស់លាស់នេះគួរឲ្យព្រួយបារម្ភ។ យើងខ្ញុំទាំងអស់គ្នាសូមសំណូមដោយទទួច ដល់រដ្ឋាភិបាលសូមលោកមេត្តានៅបើកចំហចំពោះប្រភេទផ្សេងៗរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស មិនមែនសម្រាប់តែអង្គការណាដែលផ្តល់ជំនួយជាក់លាក់ប៉ុណ្ណោះទេ។ យើងខ្ញុំទាំងអស់គ្នាសូមសំណូមដោយទទូចដល់រដ្ឋាភិបាលសូមលោកមេត្តានៅបើកចំហចំពោះប្រភេទផ្សេងៗ របស់អង្គការមិនមែនរដ្ឋាភិបាលបរទេសមិនមែនសម្រាប់តែ អង្គការណា ដែលផ្តល់ជំនួយជាក់លាក់ប៉ុណ្ណោះទេ។[៧]

---

[៦] យើងទទួលស្គាល់ថា ខចែងមួយចំនួនក្នុងសេចក្តីព្រាងច្បាប់នេះបានប្រើប្រាស់រួច ហើយក្នុងអនុស្សរណៈយោគយល់គ្នាជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលបរទេស ទោះបី ស្ថិតក្នុងទម្រង់ខុសគ្នាបន្តិចបន្តួចក៏ដោយ។ វាមិនមានការផ្លាស់ប្តូរធាតុពិត ដែលថាខចែងទាំងនេះ មានការណែនាំខុសឆ្គងវាមិនមានន័យថា អាចទទួលយកបានក្នុងការការពារខចែង ជានីតិកម្មអចិន្ត្រៃយ៍នោះឡើយ។ លើសជាងនេះទៀត ខចែងនៅក្នុងសេចក្តីព្រាងច្បាប់នេះ គឺធ្ងន់ធ្ងរជាងខចែងក្នុងអនុស្សរណៈយោគយល់គ្នាទៅទៀត។ ឧទាហរណ៍ អនុស្សរណៈនាពេលបច្ចុប្បន្ននេះ កំណត់តម្លៃរដ្ឋបាល ២៥ ភាគរយ ប៉ុន្តែរាប់បញ្ចូលទាំងប្រាក់ខែរបស់បុគ្គលិក និងនាយករបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស។ មាត្រា១៥ នៃសេចក្តីព្រាងច្បាប់របស់អង្គការមិនមែនរដ្ឋាភិបាលកំណត់ ២៥ ភាគរយ រាប់បញ្ចូលទាំងប្រាក់ខែ បរិក្ខាការិយាល័យ និងការចំណាយផ្សេងៗទៀតសម្រាប់មុខងារការិយាល័យ។

[៧] ក៏មានភាពខុសគ្នារវាងអង្គការក្នុងស្រុក និងអង្គការបរទេស នៅពេលដែលមានការចែកទ្រព្យ ក្រោយពីការរំលាយចោល ដោយអចេតនាណាមួយ។ ទ្រព្យរបស់អង្គភាពក្នុងស្រុកមានការចែករំលែកទៅតាមសេចក្តីសម្រេចរបស់តុលាការ មិនមែនទៅតាមច្បាប់របស់អង្គភាពនោះទេ (មាត្រា ២៨) ។ សម្រាប់អង្គការបរទេស ទ្រព្យមានការចែករំលែកទៅតាមទិសដៅរបស់អង្គការបរទេស (មាត្រា២៩)

## តើក្រមរដ្ឋប្បវេណីនឹងទៅជាយ៉ាងណា?

ចុងក្រោយបង្អស់ តើពង្រាងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងប៉ះពាល់ដល់ក្រមរដ្ឋប្បវេណីដូចម្ដេច?

មាត្រា៣៤ នៃច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបានអះអាងថា បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។ ដូច្នេះ បទបញ្ញត្តិ នេះ អាចនឹងធ្វើឲ្យនិរាករណ៍ដល់បទបញ្ញត្តិក្រមរដ្ឋប្បវេណីមួយចំនួន ដែលស្ដីពីការបង្កើត និងការចុះឈ្មោះសំរាប់នីតិបុគ្គលមិនយកចំណេញ និងនីតិបុគ្គលបំរើផលប្រយោជន៍សាធារណៈ។ បទបញ្ញត្តិក្រមរដ្ឋប្បវេណី មានភាពងាយស្រួលជាងបទបញ្ញត្តិសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាការពិតមិនច្បាស់លាស់ថា តើមានបទបញ្ញត្តិស្ដីពីការចុះ ឈ្មោះស្ដីពីនីតិបុគ្គលមិនយកចំណេញ និងនីតិបុគ្គលបំរើផលប្រយោជន៍សាធារណៈរបស់ក្រមរដ្ឋប្បវេណី ដែលមិនទាន់ចូលជាធរមាននៅឡើយអាចយកមកអនុវត្តបានឬទេ នៅពេលអនាគត? នេះធ្វើឲ្យកាន់តែមានការភាន់ច្រឡំនៅក្នុងបរិស្ថានផ្លូវច្បាប់នៅកម្ពុជា ដែលបានអះអាងថា ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ គឺមានភាពងាយស្រួលយល់។

□□□